ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ៣ ខែកញ្ញា ២០១៦ តម្លៃ ១.៥០០៛

# ឋានៈ តួនាទី និងអំណាចៈ ទំនាក់ទំនងរវាងអំណាចក្នុងគ្រួសារ និងការចូលរួមរបស់ស្ត្រីក្នុងគម្រោងលើកកម្ពស់ជីវភាព

## សេចក្ដីផ្ដើម

តើការងារក្រៅផ្ទះរបស់ស្ត្រី រួមទាំងការងារជាមន្ត្រីរាជការ ឬការងារទទួលប្រាក់កម្រៃផ្សេងទៀត អាចធ្វើឲ្យគាត់មានឥទ្ធិពលនៅក្នុងគ្រួសារច្រើនជាងមុនដែរឬទេ? ថ្វីបើមានការឯកភាពជាទូទៅថា ការចូលរួមរបស់ស្ត្រីផ្ដល់ផលវិជ្ជមានដល់ទំនាក់ទំនងយេនឌ័រខ្លះ ក៏ការចូលរួមនេះ មិនអាចនាំឲ្យមានសមភាពផ្នែកយេនឌ័រដោយស្វ័យប្រវត្តិនោះដែរ។ ហេតុបច្ច័យនៃការងារក្រៅផ្ទះរបស់ស្ត្រី មានច្រើនប្រភេទផ្សេងៗគ្នា និងមានលក្ខណៈស្មុគស្មាញ។ ក្នុងប្រវត្តិសាស្ត្រសង្គមខ្មែរ ស្ត្រីតែងចូលរួមយ៉ាងសកម្មក្នុងវិស័យសេដ្ឋកិច្ច ដូចមានចុះក្នុងកំណត់ត្រានៅចុងសតវត្សរ៍ទី១៣ របស់ជីវតាក្វាន់ (Chou 1967)។ ទោះយ៉ាងនេះក្ដី ស្ត្រីនៅតែមានឋានៈទាបជាងបុរស ទាំងក្នុងគ្រួសារ និងក្នុងសង្គម ដែលជាប្រការមួយធ្វើឲ្យពួកគាត់ចាញ់ប្រៀបគេ ទាំងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងក្នុងអាជីពការងារ (MOWA 2014)។



ស្ត្រីតែងចូលរួមយ៉ាងសកម្មក្នុងវិស័យសេដ្ឋកិច្ច ប៉ុន្តែស្ត្រីនៅតែមានឋានៈទាបនៅកម្ពុជា។ ខេត្តតាកែវ ខែមករា ឆ្នាំ២០១៦

កំណើនចំនួនស្ត្រីកាន់តួនាទីដឹកនាំក្នុងជួររដ្ឋាភិបាល ឬក្នុងចលនាទាមទារសិទ្ធិផ្សេងៗ មិនបានធានាឲ្យមានសមភាពយេនឌ័រក្នុងសង្គមនោះទេ (Markham 2013; LICADHO 2014; Domingo et al. 2015)។ ដោយឡែក ថ្វីបើឱកាសរកប្រាក់ចំណូល អាចញ៉ាំងឲ្យស្ត្រីមានអំណាចគ្រប់គ្រងផ្នែកហិរញ្ញវត្ថុក៏ពិតមែន តែក៏មិនមែនមានន័យថា គាត់មានឥទ្ធិពលច្រើនទៅលើកិច្ចការផ្សេងទៀតនៅក្នុងគ្រួសារឡើយ (Malhotra and Mather 1997; Doss 2013)។ មួយវិញទៀត ទោះបីការងារក្រៅផ្ទះរបស់ស្ត្រី អាចនាំឲ្យអំពើហិង្សាក្នុងគ្រួសារថយចុះ ឬផ្ដល់លទ្ធភាពឲ្យស្ត្រី អាចដើរចេញពីចំណងអាពាហ៍ពិពាហ៍ដែលមានភាពហិង្សា (Kabeer 1997) ប៉ុន្តែវាក៏អាចបង្កើន ឬបំផុសឲ្យមានអំពើហិង្សាលើសមុនផងដែរ (Hughes et al. 2015)។ នៅក្នុងសង្គមខ្លះ ដូចជា នៅកម្ពុជា និងថៃ ទោះបីស្ត្រីមានប្រាក់ចំណូល ឬតួនាទីក្នុងស្ថាប័នរដ្ឋក៏ដោយ ក៏ក្រឹត្យក្រម និងរបៀបរបបផ្នែកសង្គមវប្បធម៌ អាចមានឥទ្ធិពលខ្លាំងក្នុងការកំណត់ទំនាក់ទំនងអំណាចរវាងបុរសនឹងស្ត្រី (Mutakalin 2008; Pen 2016)។

បើយោងតាម ឯកសារស្រាវជ្រាវនៅក្នុងបរិបទវប្បធម៌នានា យើងអាចសន្និដ្ឋានបានថា លទ្ធភាពរបស់ស្ត្រីក្នុងការដឹកនាំ

អត្ថបទនេះ រៀបចំដោយបណ្ឌិត ប៉ែន រ៉ានី អ្នកស្រាវជ្រាវ ផ្នែកអភិបាលកិច្ចនៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ Pen Rany. 2016. “Status and Power: Linking Household Power Dynamics with Women’s Participation in Livelihood Projects.” Cambodia Development Review 20(3): 1-5។ ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

ឋានៈ តួនាទី និងអំណាចរបស់ស្ត្រី ........................................ ១
ការចូលរួមរបស់និស្សិតក្នុងការអប់រំ STEM៖
និន្នាការសាកល និងផលប៉ះពាល់សម្រាប់កម្ពុជា ............... ៦
ស្តង់ដាគុណភាពទឹកកម្ពុជាផ្សេងៗ៖ ការពិនិត្យពីភាពជាប់
ទាក់ទងគ្នាចុះឡើង ................................................... ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................ ១៨
— ស្ថានភាពក្នុងប្រទេស........................ ២០
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៨

គ្រប់គ្រង ឬរកប្រាក់ចំណូល រួមទាំងលទ្ធភាពប្រើប្រាស់ចាត់ចែងប្រាក់ចំណូលរបស់ខ្លួន មិនមែនជាកត្តាតែមួយគត់ដែលជំរុញឲ្យមានការផ្លាស់ប្តូរទំនាក់ទំនងផ្នែកយេនឌ័រនោះទេ។ ការផ្លាស់ប្តូរក៏អាស្រ័យផងដែរទៅលើកត្តាផ្សេងទៀត ដូចជា ទំនាក់ទំនងរបស់ស្ត្រីជាមួយក្រុមគ្រួសារ និងស្ត្រីឯទៀត ប្រភេទការងារ និងសកម្មភាពសង្គមរបស់គាត់ រួមជាមួយឥទ្ធិពលផ្នែកសេដ្ឋកិច្ច សង្គមវប្បធម៌ និងកត្តាខាងក្រៅផ្សេងៗទៀត (Sultana 2013)។ ក្រៅពីនេះ នៅមានចំណុចផ្សេងទៀតដែលគួរយកចិត្តទុកដាក់ ដូចជា តើទំនាក់ទំនងយេនឌ័រមានការផ្លាស់ប្តូរកម្រិតណា? តើសេចក្តីសម្រេចប្រភេទណាដែលស្ត្រីអាចធ្វើបាន? តើទំនាក់ទំនងផ្នែកយេនឌ័រក្នុងគ្រួសារណាខ្លះដែលមិនមានការផ្លាស់ប្តូរដោយសារតែឥទ្ធិពលនៃក្រឹត្យក្រមប្រពៃណី។

ដើម្បីស្វែងយល់ពីការផ្លាស់ប្តូរក្នុង ទំនាក់ទំនងយេនឌ័រក្នុងគ្រួសារខ្មែរ អត្ថបទនេះពិនិត្យលើករណីសិក្សាមួយស្តីពី ការចូលរួមរបស់ស្ត្រីក្នុង គម្រោងលើកកម្ពស់ជីវភាពនៅតាមជនបទ។ ក្នុងនេះនឹងមានការពិនិត្យថា តើអំណាចក្នុងការចរចាក្នុងគ្រួសារណាខ្លះដែលមានការផ្លាស់ប្តូរ ក្រោយពីស្ត្រីបានចូលរួមក្នុងគម្រោងខាងលើ និងតើអ្វីខ្លះជាកត្តាជំរុញឬរាំងស្ទះដល់ ការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រនេះ។ ការវិភាគផ្តោតជាសំខាន់ទៅលើគម្រោងលើកកម្ពស់ជីវភាពដែលអនុវត្តដោយ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាជាង ការងារយកប្រាក់កម្រៃ ឬការងាររដ្ឋ ដោយសារហេតុផលបីយ៉ាង៖ ១) គោលដៅរបស់គម្រោងលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ គឺផ្តោតលើការកសាងសមត្ថភាពស្ត្រីក្នុងការបង្កើនផលិតកម្មកសិកម្ម សន្តិសុខស្បៀង និងប្រាក់ចំណូល ២) គម្រោងទាំងនេះតែងមានបង្កប់នូវទស្សនៈយេនឌ័រ និង ៣) នៅតាមទីជនបទ មិនសូវមានការងារមានប្រាក់កម្រៃអ្វីច្រើនក្រៅពីការងារកសិកម្មតាមរដូវកាលនោះទេ។

## សាវតារនៃការសិក្សា

អត្ថបទនេះផ្អែកលើ ការសិក្សាស្រាវជ្រាវបែបគុណភាព ដែលបានធ្វើនៅចន្លោះពីឆ្នាំ២០១៣ និង ២០១៥ នៅខេត្តបាត់ដំបង កំពង់ស្ពឺ និងមណ្ឌលគិរី ក្នុងគម្រោងសិក្សាថ្នាក់បណ្ឌិតរបស់អ្នកនិពន្ធ (Pen 2016) ដោយមានការធ្វើសម្ភាសន៍ជាមួយកសិករ ៨៧នាក់ (ស្ត្រី ៥៥នាក់) និងការពិភាក្សាតាមក្រុម។ ព័ត៌មានផ្សេងទៀតបានប្រមូលតាមការសង្កេតពិនិត្យ ការជួបប្រជុំក្នុងសហគមន៍ និងការជជែកគ្នាក្រៅផ្លូវការជាមួយអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ក្នុងរយៈពេលជាង ៦ខែនៃការចុះសិក្សាដល់មូលដ្ឋាន។ នៅក្នុងភូមិដែលបានធ្វើការសិក្សា សុទ្ធតែមានគម្រោងអភិវឌ្ឍន៍កំពុងអនុវត្តដោយ NGOs ដូច្នេះហើយអ្នកចូលរួមក្នុងការសិក្សាភាគច្រើនសុទ្ធតែបានទទួលផលពីគម្រោង ក្នុងនោះមាន ៦៨នាក់ (ស្ត្រី ៤៤នាក់) បានចូលរួមក្នុងក្រុមសន្សំប្រាក់ ធនាគារស្រូវ ធនាគារគោ ឬ សហគមន៍ព្រៃឈើ។

ការសិក្សានេះផ្តោតសំខាន់តែលើ ស្ត្រីជាមេគ្រួសារប៉ុណ្ណោះ ដោយសារភាគច្រើននៃសមាជិករបស់ក្រុមខាងលើ គឺជាគ្រួសារដឹកនាំដោយស្ត្រី ព្រោះក្នុងចំណោមស្ត្រីដែលបានផ្តល់សម្ភាសន៍ទាំង ៥៥នាក់ មាន ២១នាក់ជាមេគ្រួសារតែម្នាក់ឯង (ឬ ៣៨,២%) និង ៧នាក់ជាសហមេគ្រួសារមានឋានៈ ស្មើនឹងប្តីរបស់គាត់ គឺច្រើនជាងអត្រាមធ្យមថ្នាក់ជាតិដែលមានត្រឹម ២៥,៦% (NIS 2008)។ ការដែលស្ត្រីភាគច្រើនចូលរួមក្នុងក្រុមខាងលើ បានបំផុសសំណួរថា ១) តើឥទ្ធិពលគម្រោងធ្វើឲ្យស្ត្រីផ្លាស់ប្តូរស្ថានភាពពីមេផ្ទះ ទៅជាមេគ្រួសារ ឬយ៉ាងណា? ២) តើការចូលរួមក្នុងគម្រោង បានជួយបង្កើនសុខមាលភាព និងសិទ្ធិអំណាចរបស់ស្ត្រីក្នុងការចរចានៅក្នុងគ្រួសារដែរឬទេ?

ការវិភាគផ្អែកលើទស្សនាទានរបស់ Kabeer (1999, 435) ដែលបានឲ្យនិយមន័យការផ្តល់ភាពអង់អាចក្លាហាន ថាជា "ដំណើរការមួយ ដែលតាមរយៈនោះ អ្នកដែលមិនធ្លាប់មានលទ្ធភាព ធ្វើជម្រើសជាយុទ្ធសាស្ត្រសម្រាប់ជីវិតខ្លួន បានទទួលនូវលទ្ធភាពបែបនេះ"។ Kabeer កំណត់ធាតុផ្សំបីនៃអំណាចដែលជាប់ប្រទាក់ក្រឡាគ្នា គឺមាន ធនធាន សមត្ថភាពក្នុងការធ្វើ ឬទាមទារអ្វីមួយ (Agency) និង ផលសម្រេច (ឬសុខមាលភាព)។ លទ្ធភាពទទួលបាន និងការត្រួតត្រាលើធនធាន (ទាំងផ្នែកសម្ភារ សង្គម និងចំណេះដឹង) ជួយបង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការជ្រើសរើសអ្វីមួយ។ រីឯធាតុផ្សំទី២ សំដៅដល់ សមត្ថភាពរបស់ស្ត្រីក្នុងការកំណត់គោលដៅជីវិតខ្លួន និងសម្រេចគោលដៅនោះតាមរយៈការចរចា ការជំទាស់តទល់ ឬការបញ្ចុះបញ្ចូល។ ធាតុផ្សំទី១ និង ទី២ (ធនធាន និង សមត្ថភាព) កំណត់ពីសមត្ថភាពរបស់ស្ត្រីក្នុងការជ្រើសរើសធ្វើអ្វីដែលខ្លួនឲ្យតម្លៃខ្ពស់ រីឯធាតុផ្សំទី៣ គឺផលសម្រេច អាចពិបាកមើលឃើញនិងវាស់វែងបាន ពីព្រោះនៅក្នុងបរិបទខុសៗគ្នា ការឲ្យតម្លៃ ទៅលើអ្វីមួយក៏ខុសគ្នាដែរ។

## ស្ត្រីជាមេគ្រួសារ៖ ជាករណីលើកលែង ឬយ៉ាងណា?

ការស្វែងយល់ ពីន័យរបស់ពាក្យ "មេគ្រួសារ" និង "មេផ្ទះ" អាចជួយបំភ្លឺលើបញ្ហា វិសមភាពយេនឌ័រ ក្នុងគ្រួសារ។ ការឲ្យនិយមន័យ និងការប្រើប្រាស់ពាក្យទាំងនេះ ក្នុងជីវិតប្រចាំថ្ងៃ អាចជួយបង្កើន ឬពង្រឹងវិសមភាពយេនឌ័រ។ តួយ៉ាង ពាក្យ មេគ្រួសារ និង មេផ្ទះ មានបង្កប់អត្ថន័យខុសគ្នានៃលំដាប់ឋានានុក្រម តម្លៃ និងភារកិច្ចដែលជាប់មកជាមួយតួនាទីទាំងនេះ។ ពាក្យ "មេ" មានន័យថា ម្តាយ ឬអ្នកមានសិទ្ធិអំណាចខ្ពស់ ឬមានតួនាទីដូចអ្នកគ្រប់គ្រង។ ពាក្យ "គ្រួសារ" សំដៅលើ ក្រុមមនុស្សរស់នៅក្នុងផ្ទះ (ឪពុក-ម្តាយ-កូន) ឬប្រជុំត្រកូលមនុស្សជាប់សែស្រឡាយនឹងគ្នា ឯពាក្យ "ផ្ទះ" គឺជា លំនៅដ្ឋានរូបវន្តសម្រាប់គ្រួសារ។

តាមធម្មតា បុរសជាប្តីមានឋានៈជា "មេគ្រួសារ" (Lee 2006) ជាអ្នកចាត់ចែងលើសមាជិកគ្រួសារ និង មានទំនួលខុសត្រូវលើសុខមាលភាពផ្នែកស្មារតី និងសម្ភាររបស់សមាជិកគ្រួសារម្នាក់ៗ (Mao and Vann 2010) ។ គាត់មានសិទ្ធិអំណាច គ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ (NIS 2008)។ "មេផ្ទះ" ជាឋានៈតួនាទីដែលផ្តល់ទៅឲ្យស្ត្រីដែលរៀបការរួច។ ក្នុងនាមជាមេផ្ទះ គាត់មានតួនាទីចាត់ចែង និងធ្វើកិច្ចការក្នុងផ្ទះ ទៅតាមប្រពៃណីខ្មែរ (Chuon 1967)។

ដោយសារជំរឿនថ្នាក់ជាតិ បានរកឃើញថា គ្រួសារដែលមានមេគ្រួសារជាបុរសមានចំនួនច្រើនលើសលប់ (NIS 2008,

2015) ដូច្នេះយើងបានសន្និដ្ឋានថា ស្ត្រីទទួលបានឋានៈជាមេគ្រួសារតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ តួយ៉ាង ក្នុងចំណោមអ្នកចូលរួម ស្ត្រីខ្លះបានក្លាយជាមេគ្រួសារក្រោយពេល ប្តីស្លាប់ ប្តីបោះបង់ចោល ឬក្រោយការលែងលះគ្នា។ ស្ត្រីខ្លះទៀតក្លាយជាមេគ្រួសារ ក្រោយប្តីមានជំងឺមិនអាចធ្វើការបាន។ ការធ្វើចំណាកស្រុករបស់ប្តី ក៏នាំឲ្យមានការផ្លាស់ប្តូរតួនាទីយេនឌ័រដែរ ដោយប្រពន្ធនៅឯផ្ទះត្រូវធ្វើជាមេគ្រួសារបណ្តោះអាសន្ន ដូចក្នុងករណី អ្នកស្រី ទឹម អាយុ ៣៣ឆ្នាំ នៅខេត្តកំពង់ស្ពឺ ដែលប្តីគាត់បានធ្វើចំណាកស្រុកទៅប្រទេសថៃ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៀត គឺស្ត្រីមួយចំនួនបានដឹកនាំគ្រួសារ មិនមែនដោយសារមូលហេតុខាងលើទេ ប៉ុន្តែដោយសារគាត់មានទ្រព្យសម្បត្តិ និងការអប់រំច្រើនជាងប្តីរបស់គាត់ ឬដោយសារឋានៈនៅក្នុងសង្គមរបស់ គ្រួសារឪពុកម្តាយរបស់គាត់។ ឧទាហរណ៍ អ្នកស្រី គន្ធា អាយុ ៣០ឆ្នាំ និងជាមេគ្រួសារ បានទទួលមរតកជាផ្ទះ និងដីស្រែចំការពីឪពុកម្តាយរបស់គាត់ រីឯបុរសជាប្តីបានផ្លាស់លំនៅពីឃុំផ្សេង មករស់នៅជាមួយគាត់ដោយមិនមានទ្រព្យអ្វីមកជាមួយ។ ដោយឡែក អ្នកស្រី ស បានក្លាយជាមេគ្រួសារមានសមាជិក ៩នាក់ ដោយសារហេតុផលផ្សេងមួយទៀត។ អ្នកស្រី ជាមនុស្សពូកែនិយាយ និងចេះអក្សរ ហើយគាត់បានមករស់នៅខេត្តកំពង់ស្ពឺ ជាមួយប្តីគាត់ដែលមិនសូវចេះអាន និងចេះសរសេរ។ អ្នកស្រី ស បានបម្រើក្នុងជួរកងទ័ពក្នុងទសវត្សរ៍១៩៨០ និងបានធ្វើសកម្មភាពនយោបាយតាំងពីពេលនោះមក។ គាត់ក៏ជាមេភូមិ និងជាប្រធានក្រុមជួយខ្លួនឯង ផងដែរ។

មូលហេតុមួយទៀតដែលនាំឲ្យ អត្រាគ្រួសារមានមេគ្រួសារជាស្ត្រីនៅក្នុងការសិក្សា វាខ្ពស់ជាង អត្រាមធ្យមថ្នាក់ជាតិ គឺដោយសារស្ត្រីភាគច្រើនដែលបានផ្តល់បទសម្ភាសន៍ បានអះអាងថា ខ្លួនគាត់ផ្ទាល់ជាមេគ្រួសារ ឬសហមេគ្រួសារមានឋានៈស្មើប្តីរបស់គាត់។ ការឆ្លើយដូច្នេះអាចបណ្តាលមកពី របៀបសួរសំណួរនៅពេលធ្វើសម្ភាសន៍។ តួយ៉ាង អ្នកចូលរួមទាំងអស់មានសេរីភាពក្នុងការកំណត់និយមន័យពាក្យមេគ្រួសារ ដោយផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន មិនមែនផ្អែកតាមការកត់ត្រាក្នុងសៀវភៅគ្រួសារនោះទេ។ សម្រាប់ស្ត្រីដូចបញ្ជាក់នៅខាងលើ កត្តាដែលគាត់គ្រប់គ្រងចាត់ចែងលើគ្រួសារទាំងមូល ក៏ដូចជា មើលថែទាំកូន ទុកដាក់និងគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ និងរកប្រាក់ចំណូលដោយខ្លួនឯង វាគ្រប់គ្រាន់ណាស់ទៅហើយដើម្បីអះអាងថា ខ្លួនគាត់ជាមេគ្រួសារ និងមានឋានៈស្មើប្តីរបស់គាត់។

ការរៀបរាប់ពីបទពិសោធន៍ជាមេគ្រួសារខាងលើ បង្ហាញថា ការចូលរួមរបស់ស្ត្រីក្នុងគម្រោងលើកកម្ពស់ជីវភាព មិនមែនសុទ្ធតែនាំឲ្យមានការប្រែប្រួលក្នុងទំនាក់ទំនងយេនឌ័រ ឬធ្វើឲ្យស្ត្រីក្លាយជាមេគ្រួសារនោះទេ។ ស្ត្រីដែលបានចូលរួមផ្តល់បទសម្ភាសន៍ជាច្រើននាក់ មានតួនាទីជាមេគ្រួសារ មុនពេលគាត់ចូលរួមក្នុងគម្រោង។ ទោះយ៉ាងណាក្តី ទំនាក់ទំនងសិទ្ធិអំណាចក្នុងគ្រួសារ តែងមានភាពស្មុគស្មាញជាងនេះ និងប្រែប្រួលជានិច្ច។ ម្យ៉ាងទៀត ការក្លាយជាមេគ្រួសារ មិនមែនមានន័យថា ស្ត្រីមានសិទ្ធិអំណាចច្រើនថែមទៀតនោះទេ។ ការពិភាក្សាខាងក្រោមនេះបង្ហាញពីការផ្លាស់ប្តូរ បន្ទាប់ពីស្ត្រីទៅចូលរួមក្នុងគម្រោងលើកកម្ពស់ជីវភាពគ្រួសារ។

## ការវាស់វែងការផ្លាស់ប្តូរៈ ធនធាន សមត្ថភាព (agency) និង សុខមាលភាព

កត្តាប្រែប្រួលលឿនជាងគេ គឺលទ្ធភាពរបស់អ្នកចូលរួមក្នុងការទទួលបានធនធានផ្សេងៗផ្តល់ឡើងដោយគម្រោង ដូចជា ការបណ្តុះបណ្តាលជំនាញផ្នែកកសិកម្ម ការអប់រំផ្នែកសុខភាពនិងអនាម័យ កម្ចីគ្មានការប្រាក់ និង ការទទួលបានគ្រាប់ពូជ សត្វចិញ្ចឹម ស្បៀង និងសម្ភារសម្រាប់សាងសង់ឬជួសជុលលំនៅស្ថាន ។

ក្រៅពីនេះក៏មានការផ្លាស់ប្តូរក្នុងការប្រើសមត្ថភាព ដើម្បីធ្វើសេចក្តីសម្រេចចិត្ត តាមរយៈ ការចូលរួម ការចរចា ការជំទាស់តទល់ និងការបញ្ចុះបញ្ចូល។ ថ្វីបើការផ្លាស់ប្តូរអំណាចក្នុងការចរចារបស់ស្ត្រីក្នុងគ្រួសារអាចពិបាកវាស់វែង ក៏ពិតមែន ប៉ុន្តែស្ត្រីដែលជាមេគ្រួសារ ឬសហមេគ្រួសារ បានលើកឡើងថា គាត់មានភាពជឿជាក់ និងស្វ័យភាពជាងមុន ក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការងារកសិកម្ម ការចំណាយក្នុងគ្រួសារ ក៏ដូចជាការថែទាំសុខភាព ការធ្វើដំណើរ និងការទិញទំនិញប្រើប្រាស់ផ្ទាល់ខ្លួន។ ទោះយ៉ាងណាក្តី សេចក្តីសម្រេចធំៗ ដូចជាការទិញលក់ដីធ្លី ផ្ទះ បរិក្ខារកសិកម្ម ឬការធ្វើចំណាកស្រុក នៅតែជាសេចក្តីសម្រេចចិត្តរួមគ្នារវាងប្តីប្រពន្ធ ដូចក្នុងករណី អ្នកស្រី ទឹម ដែលប្តីគាត់បានធ្វើចំណាកស្រុកទៅប្រទេសថៃ ជាដើម។

អត្ថប្រយោជន៍សំខាន់មួយទៀតរបស់ក្រុមជួយខ្លួនឯង គឺការពង្រឹងទំនាក់ទំនងបណ្តាញសង្គមរបស់ស្ត្រី (Basargekar 2010; Hiwasa 2013)។ ក្នុងករណីសិក្សានេះ ក្រុមនីមួយៗបានផ្តល់ឱកាសឲ្យស្ត្រីស្គាល់គ្នា និងកសាងបណ្តាញគាំទ្រគ្នាទៅវិញទៅមក។ ស្ត្រីដែលជាអ្នកទទួលផលពីគម្រោងផង និងជាប្រធានក្រុមផង តែងមានឱកាសកាន់តែច្រើនជាងសមាជិកធម្មតា។ ចាប់ផ្តើមពីជំនាញសាមញ្ញៗដូចជា អក្ខរកម្ម ពួកគាត់បានរៀនជំនាញដឹកនាំ និងជំនាញក្នុងការនិយាយស្តីជាសាធារណៈ ហើយជំនាញទាំងនេះចាំបាច់ណាស់ សម្រាប់ធ្វើការតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន។ ជាលទ្ធផល ស្ត្រីមួយចំនួន បានក្លាយជាអ្នកសកម្មខាងនយោបាយនៅតាមមូលដ្ឋាន និងត្រូវគេបោះឆ្នោតឲ្យចូលក្នុងក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (Banteay Srei 2013)។

នៅពេលស្ត្រីមានធនធានផ្នែកសម្ភារ ហិរញ្ញវត្ថុ មានចំណេះដឹង និងមានបណ្តាញទំនាក់ទំនងច្រើននៅក្នុងសង្គម គាត់មានជំហររឹងមាំ និងអាចក្រោកឈរដោយខ្លួនឯងបាន ប្រសិនបើគាត់ជួបឧបសគ្គនាពេលអនាគត។ យោងតាម Agarwal (1997) ប្រសិនបើស្ត្រីត្រូវបាត់បង់ប្តី ឬបាត់បង់ការទុកចិត្តគ្នាទៅវិញទៅមកក្នុងគ្រួសារ ស្ត្រីទាំងនោះនៅតែមានជម្រើសផ្សេងៗទៀតសម្រាប់ជីវិតរបស់គាត់។ ករណីនេះកើតមានលើ អ្នកស្រី គីមម៉ៅ អាយុ ៥០ឆ្នាំ មានកូន ៥នាក់ មកពីខេត្តបាត់ដំបង។ គាត់ចូលរួមក្នុងក្រុមស្ត្រីជួយខ្លួនឯងនៅដើមទសវត្សរ៍២០០០។ពីដំបូងអ្នកស្ត្រីមិនចេះអក្សរទេ ហើយបុគ្គលិក NGO បានលើកទឹកចិត្តឲ្យអ្នកស្រីរៀនអាន និងសរសេរ ដើម្បីអាចមានតួនាទីកាន់តែសកម្មនៅក្នុងក្រុម។ ពេលរៀនចេះ អ្នកស្រីបានចាប់ផ្តើមធ្វើជាអ្នកស្ម័គ្រចិត្ត

សម្របសម្រួលសកម្មភាពក្នុងក្រុមរបស់គាត់។ អ្នកស្រី គីមម៉ៅ មិនចង់រំលឹកដល់អតីតកាលប៉ុន្មានទេ ព្រោះគាត់ធ្លាប់ឆ្លងកាត់ភាពចម្រូងចម្រាស់នៅក្នុងគ្រួសារអស់ជាច្រើនឆ្នាំ។ ប្ដីរបស់គាត់បានបោះបង់គាត់ចោល និងទុកឲ្យគាត់ចិញ្ចឹមកូនទាំង ៥នាក់ តែម្នាក់ឯង។ នៅពេលសម្ភាសន៍ កូនស្រីពៅរបស់អ្នកស្រីរៀនដល់ថ្នាក់ទី៩ ហើយកូនច្បង ២នាក់ ធ្វើជាគ្រូបង្រៀន។ ថ្មីៗនេះ ប្ដីរបស់គាត់បានត្រឡប់មករស់នៅជុំគ្រួសារវិញ ហើយគាត់ក៏បានប្រគល់តួនាទីជាមេគ្រួសារទៅឲ្យប្ដីគាត់។ ទោះយ៉ាងណាក្ដី អ្នកស្រី គីមម៉ៅ នៅតែរក្សាតួនាទីជាអាណាព្យាបាលគ្រប់គ្រងលើកូនៗ និងបន្តធ្វើជាអ្នកសម្រេចចិត្តដ៏សំខាន់ក្នុងគ្រួសារ។ អង្គុយមិនឆ្ងាយពីប្ដីរបស់ខ្លួន អ្នកស្រី គីមម៉ៅ បាននិយាយដោយឥតស្ទាក់ស្ទើរថា៖

> នៅពេលគេ [អាជ្ញាធរ] ឲ្យសរសេរឈ្មោះមេគ្រួសារលើឯកសារផ្លូវការ ខ្ញុំដាក់ឈ្មោះប្ដីខ្ញុំ។ ប៉ុន្តែតាមពិត ខ្ញុំជាមេគ្រួសារ។ ខ្ញុំគ្រប់គ្រងសព្វគ្រប់ទាំងអស់ដោយខ្លួនឯង។ ខ្ញុំខំធ្វើការដើម្បីផ្គត់ផ្គង់កូនៗឲ្យទៅសាលារៀន រហូតដល់បានធ្វើគ្រូបង្រៀន។ មេគ្រួសារពិតប្រាកដ គឺខ្ញុំ។ ខ្ញុំក៏ធ្វើការសម្រេចចិត្តក្នុងគ្រួសារដែរ រួមទាំងការទិញលក់របស់ធំៗផង។ គ្មានអ្នកណាហ៊ានធ្វើអ្វី ដោយគ្មានការអនុញ្ញាតពីខ្ញុំទេ។

ការផ្លាស់ប្ដូរតួនាទីផ្នែកយេនឌ័រ ដូចបានរៀបរាប់ខាងលើ បង្ហាញច្បាស់ពីសារៈសំខាន់នៃការពង្រឹង ធនធានមនុស្ស ចំណេះដឹង និងបណ្ដាញសង្គមរបស់ស្ត្រី ដែលជាធាតុផ្សំចាំបាច់មួយនៃយុទ្ធសាស្ត្រលើកស្ទួយជីវភាពគ្រួសារ។ ការផ្លាស់ប្ដូរផ្នែកសមត្ថភាព អាចមើលឃើញបាន តាមរយៈ ការបង្ហាញចេញមកក្រៅនូវមោទនភាពលើជោគជ័យរបស់ខ្លួន និងការជឿជាក់លើខ្លួនឯង។ ក្នុងករណីអ្នកស្រី គីមម៉ៅ គាត់មានមោទនភាពដោយបានរៀនសូត្រចេះអាន ចេះសរសេរ មានជំនាញធ្វើកសិកម្ម អាចរកចំណូលបានច្រើនជាងមុន និងមានការងារកាន់តែប្រសើរនៅក្នុងសហគមន៍របស់គាត់។ អ្វីដែលសំខាន់បំផុតសម្រាប់អ្នកស្រីគឺផ្លែផ្កាដែលរូបគាត់ និងគ្រួសារគាត់បានទទួល ដោយសារការខំប្រឹងធ្វើការ និងការធ្វើវិនិយោគលើការអប់រំកូនៗរបស់គាត់។

> កាលពីមុន គ្មាននរណាចង់រាប់អានយើងទេ។ ឥឡូវនេះ អ្នកភូមិនិយាយរកយើង ព្រោះខ្ញុំមានកូនធំៗ ២នាក់ ធ្វើគ្រូបង្រៀន។ ទោះបីយើងមិនមែនជាអ្នកមានក៏ដោយ តែយើងមានចំណេះដឹងដែលគ្មាននរណាអាចលួចបាន។

ការចូលរួមក្នុងក្រុមដែលជួយឲ្យមាន ការកសាងបណ្ដាញទំនាក់ទំនង និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមក រួមនឹង ការក្លាយជាមេគ្រួសារក្នុងកាលៈទេសៈដ៏លំបាក បានធ្វើឲ្យស្ត្រីមានភាពរឹងមាំ នាពេលអនាគត។ បទពិសោធន៍ទាំងនេះអាចចាត់ទុកជា "ទ្រព្យយកតាមខ្លួនបាន"។ ទ្រព្យយកតាមខ្លួនបាន ជាពាក្យដែលបង្កើតដោយ លោក Bird et al. (2010) ដោយសំដៅលើការអប់រំ និងសមត្ថភាពរបស់ស្ត្រី ក្នុងការកសាងជីវិតឡើងវិញ ក្រោយមានការបាត់បង់ទ្រព្យរូបវន្ត។ Chant (2015) បានដាក់បញ្ចូលបន្ថែមនូវបទពិសោធន៍របស់ស្ត្រីជាមេគ្រួសារថាជា ទ្រព្យយកតាមខ្លួនបាន។ ក្នុងករណីសិក្សាខាងលើ ស្ត្រីដែលមាន "ទ្រព្យយកតាមខ្លួនបាន" មានទំនុកចិត្តលើខ្លួនឯងច្រើន និង មានសមត្ថភាពសម្របខ្លួន អាចទប់ទល់នឹងឧបសគ្គផ្សេងៗដែលអាចកើតមាននាពេលអនាគត និងមិនរារែកក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន។ ជាក់ស្ដែង នៅពេលធ្វើសម្ភាសន៍ អ្នកស្រី គីមម៉ៅ មិនខ្លាចនឹងអះអាង នៅចំពោះមុខប្ដីថាខ្លួនគាត់គឺជា "មេគ្រួសារពិតប្រាកដ"។

ស្ត្រីជាមេគ្រួសារ ជាអ្នកដឹកនាំក្នុងសហគមន៍ និងបានរៀនសូត្រយល់ដឹងពី សិទ្ធិមនុស្ស និងសមភាពយេនឌ័រ មិនសូវអត់ទ្រាំនឹងអំពើហិង្សា ដូចស្ត្រីផ្សេងទៀតដែលស៊ូទ្រាំរងទុក្ខតែម្នាក់ឯង ព្រោះខ្លាច ការលែងលះ ឬប្ដីបោះបង់ចោល (Brickell 2014)។ ការមិនស៊ូទ្រាំនឹងអំពើហិង្សា ស្ដែងចេញតាមរយៈការយល់ឃើញរបស់គាត់ទៅលើទស្សនៈបុរាណ "ក្អមក្អើងទាំងបី"។ គាត់យល់ឃើញថា ថ្វីបើបញ្ហាគ្រួសារគួរទុកនៅក្នុងគ្រួសារក៏ពិតមែន ប៉ុន្តែអំពើហិង្សាជាការរំលោភសិទ្ធិនារីធ្ងន់ធ្ងរ និងត្រូវរាយការណ៍ទៅសមត្ថកិច្ច។

## សេចក្ដីសន្និដ្ឋាន៖ សមភាពចាប់ផ្ដើមពីក្នុងគ្រួសារ

អត្ថបទនេះ បានពិនិត្យលើទំនាក់ទំនងរវាងអំណាចចរចាក្នុងគ្រួសារ ជាមួយនឹង ការចូលរួមរបស់ស្ត្រីក្នុងគម្រោងអភិវឌ្ឍន៍សហគមន៍។ បទពិសោធន៍ជីវិតរបស់ស្ត្រីដែលបានផ្ដល់សម្ភាសន៍បង្ហាញថា ប្រភេទនៃការងារឬសកម្មភាពដែលគាត់បានចូលរួមដូចជាការងារស្ម័គ្រចិត្តក្នុងគម្រោងលើកស្ទួយជីវភាព អាចជាកត្តាចម្បងមួយ ជួយជំរុញឲ្យមានការផ្លាស់ប្ដូរក្នុងទំនាក់ទំនងយេនឌ័រក្នុងគ្រួសារ។ គម្រោងបែបនេះ មិនត្រឹមតែផ្ដល់ឲ្យស្ត្រីនូវធនធាននិងជំនាញសម្រាប់បង្កើនប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់នូវឱកាសឲ្យគាត់បង្កើត និងពង្រឹងទំនាក់ទំនងក្នុងសហគមន៍ និងការជួយទ្រទ្រង់គ្នាទៅវិញទៅមកទៀតផង។

ទោះបីការបែងចែកកិច្ចការក្នុងផ្ទះរវាង បុរសនឹងស្ត្រី សឹងតែគ្មានការប្រែប្រួល ហើយស្ត្រីនៅតែបន្តបំពេញតួនាទីជាមេផ្ទះដដែល ក៏ការកសាងឋានៈនៅក្នុងគ្រួសារ និងការចូលរួមធ្វើសេចក្ដីសម្រេចចិត្តរបស់ស្ត្រី បានឆ្លុះបញ្ចាំងពីកំណើនសិទ្ធិអំណាចរបស់គាត់ ហើយគាត់ហ៊ានជំនះលើទស្សនៈបុរសត្រូវធ្វើជាមេគ្រួសារ និងហ៊ានទាមទារថា ការរួមចំណែករបស់ខ្លួននៅក្នុងការរកប្រាក់ចំណូល និងកិច្ចការងារផ្ទះ ក៏ជាការងារសំខាន់ខ្លាំងណាស់ក្នុងការជួយទ្រទ្រង់សុខមាលភាពគ្រួសារទាំងមូល។

ដោយសារគ្រួសារជាផ្នែកមួយនៃ សង្គមដែលក្នុងនោះសមាជិកម្នាក់ៗតែងចង់បានសិទ្ធិអំណាចរៀងៗខ្លួន ការកើនឡើងខាងចំណេះដឹង ធនធានសេដ្ឋកិច្ច និងធនធានសង្គមរបស់ស្ត្រី បានផ្ដល់ឱកាសថ្មីឲ្យពួកគាត់ ហ៊ានចរចានិងប្រឈមមុខនឹង ប្រព័ន្ធបិតាធិបតេយ្យដែលនៅមាននៅឡើយនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។ ដូច្នេះ ក្នុងកិច្ចការដោះស្រាយបញ្ហាវិសមភាពយេនឌ័រក្នុងសង្គម

យើងមិនគួរមើលរំលង សារៈសំខាន់នៃគ្រួសារដែលជាកន្លែងសាបព្រោះបណ្ដុះសមភាពយេនឌ័រពិតប្រាកដនោះទេ។

ម៉្យាងទៀត ដើម្បីពង្រឹងសមត្ថភាព និងសុខមាលភាពរបស់ស្ត្រីឲ្យកាន់តែប្រសើរ ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋាភិបាលដែលធ្វើការដោះស្រាយបញ្ហាយេនឌ័រ គួរផ្ដោតឲ្យបានច្រើនលើបញ្ហាយេនឌ័រក្នុងគ្រួសារ បន្ថែមពីលើការងារលើកស្ទួយស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រីទៅទៀត។ ជាក់ស្ដែង ស្ថាប័នទាំងនេះគួរសកម្មលើកស្ទួយលទ្ធភាពរបស់ស្ត្រី ឲ្យចូលរួមយ៉ាងពេញលេញ និងស្មើភាព ក្នុងការធ្វើសេចក្ដីសម្រេចចិត្តក្នុងគ្រួសារ ព្រោះកត្តាសំខាន់បំផុតក្នុងការផ្ដល់ភាពអង់អាចដល់ស្ត្រី គឺការចូលរួមរបស់គាត់ក្នុងការសម្រេចចិត្តសំខាន់ៗពាក់ព័ន្ធដល់រូបគាត់។ សំឡេងរបស់គាត់នៅក្នុងការសម្រេចចិត្តនឹងជួយធានាថា ការសម្រេចចិត្តក្នុងគ្រួសារមិនប៉ះពាល់ដល់ប្រយោជន៍របស់គាត់ ទោះបីជួនកាលវាមិនអំណោយផលច្រើនដល់គាត់ក្ដី។ ពេលខ្លះសំឡេងរបស់គាត់នៅក្នុងការសម្រេចចិត្ត អាចជួយកាត់បន្ថយភាពរើសអើងផ្នែកយេនឌ័រក្នុងគ្រួសារទាំងមូល និងធ្វើឲ្យសមាជិកគ្រួសារទាំងស្រីទាំងប្រុសទទួលបានផលប្រយោជន៍ស្មើៗគ្នា។

ជាចុងក្រោយ គួរកត់សម្គាល់ថា ការវិភាគនេះ ជាការសិក្សាស្រាវជ្រាវផ្អែកលើបទពិសោធន៍របស់ស្ត្រី ដែលមានតួនាទីដឹកនាំក្នុងក្រុមបង្កើតឡើងដោយ គម្រោងលើកស្ទួយជីវភាពគ្រួសារ។ ទៅថ្ងៃអនាគត គួរមានការស្រាវជ្រាវបន្ថែម អំពីឥទ្ធិពលនៃក្រុមទាំងនេះទៅលើសមាជិកធម្មតា ដែលមិនមានតួនាទីក្នុងគម្រោង និងអំពីផលប៉ះពាល់ទៅលើជីវិតរស់នៅរបស់ស្ត្រី នៅពេលគាត់ចូលធ្វើការងាររកប្រាក់កម្រៃផ្សេង ក្រៅពីការងារអភិវឌ្ឍន៍សហគមន៍ ក៏ដូចជាផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍សហគមន៍ដទៃទៀត ដែលមិនបានយកចិត្តទុកដាក់លើបញ្ហាយេនឌ័រដូចគម្រោងបានសិក្សានៅខាងលើ។

## ឯកសារយោង


Agarwal, Bina. 1997. " 'Bargaining' and Gender Relations: Within and Beyond the Household." *Feminist Economics* 3(1): 1-51.

Banteay Srei. 2016. "Leup Lei, Commune Council Member." Banteay Srei. http://banteaysrei.info/casestudy/leup-lei-commune-council-member/.

Basargekar, Prema. 2010. "Measuring Effectiveness of Social Capital in Microfinance: A Case Study of Urban Microfinance Programme in India." *International Journal of Social Inquiry* 3(2): 25-43.

Bird, Kate, Kate Higgins and Andy MacKay. 2010. "Conflict, Education and the Intergenerational Transmission of Poverty in Northern Uganda." *Journal of International Development Studies* 22:1183-96.

Brickell, Katherine A. 2014. " 'Plates in a Basket Will Rattle': Marital Dissolution and Home 'Unmaking' in Contemporary Cambodia." *Geoforum* 51:262-272.

Chant, Sylvia. 2015. "Female Household Headship as an Asset? Interrogating the Intersections of Urbanisation, Gender, and Domestic Transformations." In *Gender, Asset Accumulation and Just Cities: Pathways to Tranformation*, edited by Caroline Moser, 21-39. London: Routledge.

Chou, Ta-kuan. 1967. *Notes on the Customs of Cambodia*. Translated by J. Gilman D'Arcy Paul. Bangkok: Social Science Association Press.

Chuon Nath. 1967. *Khmer Dictionary*. Phnom Penh: Buddhist Institute.

Domingo, Pilar, Rebecca Holmes, Tam O'Neil, Nicola Jones, Kate Bird, Anna Larson, Elizabeth Presler-Marshall and Craig Valters. 2015. *Women's Voice and Leadership in Decision-Making*. London: ODI.

Doss, Cheryl. 2013. "Intrahousehold Bargaining and Resource Allocation in Developing Countries." *World Bank Research Observer* 28(1): 52-78.

Hiwasa, Ayako. 2013. "Changing Gendered Boundaries in Rural Cambodia." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*, edited by Gabi Waibel, Judith Ehlert and Hart Feuer. New York: Routledge.

Hughes, Christine, Mara Bolis, Rebecca Fries and Stephanie Finigan. 2015. "Women's Economic Inequality and Domestic Violence: Exploring the Links and Empowering Women." *Gender and Development* 23(2): 279-297.

Kabeer, Naila. 1997. "Women, Wages and Intra-household Power Relations in Urban Bangladesh." *Development and Change* 28: 261-302.

Kabeer, Naila. 1999. "Resource, Agency, Achievements: Reflections on the Measurement of Women's Empowerment." *Development and Change* 30(3): 425-464.

Lee, Susan Hagood. 2006. *'Rice Plus': Widows and Economic Survival in Rural Cambodia*. New York; London: Routledge.

LICADHO. 2014. '*Good Wives': Women Land Campaigners and the Impact of Human Rights Activism.* Phnom Penh: LICADHO.

Malhotra, Anju, and Mark Mather. 1997. "Do Schooling and Work Empower Women in Developing Countries? Gender and Domestic Decisions in Sri Lanka." *Sociological Forum* 12(4): 599-630.

Mao, Veasna, and Sophy Vann. 2010. *Teachers' Aide-Mémoire: Morals and Civic Education for Primary School*. Phnom Penh: Ministry of Education, Youth and Sport.

Markham, Susan. 2013. *Women as Agents of Change: Having Voice in Society and Influencing Policy*. Women's Voice, Agency, and Participation Research Series No. 5. Washington, DC: World Bank.

MOWA (Ministry of Women's Affairs). 2014. *Leading the Way: Cambodia Gender Assessment; Excutive Summary*. Phnom Penh: MOWA.

Mutakalin, Gullinee. 2008. "Intrahousehold Bargaining Among Women Workers in Thailand's Northern Region Industrial Estate." *NIDA Economic Review*:49-71.

NIS (National Institute of Statistics). 2008. *National Population Census*. Phnom Penh: NIS.

NIS. 2015. *Census of Agriculture in Cambodia2013: National Report on Final Census Results.* Phnom Penh, Ministry of Planning, NIS.

Pen Rany. 2016. "White Gold: A Study of Gender Relations in Rural Cambodia." PhD thesis, University of Sydney.

Sultana, Umme Busra Fateha. 2013. "Revisiting 'Bargaining' – Reflections on Feminist Extensions of Sen's Household Bargaining Model: Case Studies of Gendered Labour Regime." *International Journal of Research in Humanities, Arts, and Literature* 1(2): 39-46.